# តារាងស្ដីពីព័ត៌មានរបស់គម្រោង

លេខPIP : 624

(សម្រាប់បំពេញដោយក្រសួងផែនការ)

## ព័ត៌មានមូលដ្ឋានអំពីគម្រោង

*(ត្រូវបំពេញគ្រប់ចំណុចទាំងអស់)*

## ផ្នែក ក

១. ឈ្មោះគម្រោង : ការបង្កើតមជ្ឈមណ្ឌលស្រាវជ្រាវសេនេទិចព្រៃឈើ សម្រាប់ស្តារប្រភេទឈើសំខាន់ៗនៅកម្ពុជា

២. កាលបរិច្ឆេទគម្រោង

| | |
|---|---|
| កាលបរិច្ឆេទចាប់ផ្ដើមគម្រោង | 01/01/16 |
| កាលបរិច្ឆេទបញ្ចប់គម្រោង | 31/12/25 |

៣. ចំណាយគម្រោងសរុប $1,500,000

៤. ស្ថាប័នទទួលខុសត្រូវ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

| | |
|---|---|
| RESPONSIBLE UNIT | Forestry Administration |
| អង្គភាពទទួលខុសត្រូវ | រដ្ឋបាលព្រៃឈើ |

៥. ស្ថានភាពគម្រោង គម្រោងកំពុងដំណើរការ

ព័ត៌មានលម្អិតអំពីគម្រោង

៦. ប្រភេទគម្រោង ៖ គម្រោងជំនួយបច្ចេកទេស

៧. ប្រភពហិរញ្ញប្បទាន៖ ជំនួយឥតសំណង

៨. មុំនៃគោលនយោបាយក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ ដែលគម្រោងស្ថិតនៅ

មុំទី១- ការពង្រឹង និងការកែទម្រង់ស្ថាប័ន

៩. ការចូលរួមចំណែករបស់គម្រោងក្នុងការសម្រេចបានគោលនយោបាយអាទិភាពខាងលើ

គម្រោងបានបង្កើតចំការបង្កាត់ពូជឈើដែលមានទំហំ០៦ហិកតាចំពោះប្រភេទឈើចំនួន០៣ប្រភេទ គឺគ្រញូង ធ្នង់ និងត្រាច។ ចំការបង្កាត់ពូជឈើនេះ
នឹងក្លាយជាប្រភពគ្រាប់ពូជល្អតែមួយគត់ដែរកើតឡើងពីការសម្រឹតសម្រាំងអំបូរឈើច្រើនប្រភពក្នុងព្រះរាជាណាចក្រកម្ពុជា រួមទាំងត្រូវបានជ្រើសរើសទៅតាមលក្ខខ័ណ្ឌបច្ចេកទេសរបស់គោលការណ៍ជ្រើសរើសដើមពូជឈើល្អទាំងក្នុងប្រទេសកម្ពុជា និងសាធារះរដ្ឋកូរ៉េ។ ការងារនេះ ឆ្លើយតបយ៉ាងមុតមាំទៅលើគោលនយោបាយស្តារព្រៃឈើឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

## ១០. ការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

តើគម្រោងនេះគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាដែរឬទេ? មិនគាំទ្រ

១១. វិស័យ (សូមប្រើវិស័យ អនុវិស័យ ដែលមានចែងក្នុងផ.យ.អ.ជ. )

បរិស្ថាន និងការអភិរក្ស

**១២. ទីតាំងអនុវត្តគម្រោង** ( ពិពណ៌នាពីទីតាំងដែលត្រូវអនុវត្តគម្រោង )

សៀមរាប,

**១៣. គោលបំណងរបស់គម្រោង** ( ពិពណ៌នាគោលបំណងចម្បងៗរបស់គម្រោង )

១. អនុវត្តផែនការបង្កាត់ពូជឈើរយៈពេលយូរ
២. ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើ លើការងារបង្កាត់ពូជឈើ និងស្តារព្រៃឈើ

**១៤. ការពិពណ៌នាអំពីគម្រោង** ( ពិពណ៌នាអំពីសមាសភាគទាំងអស់របស់គម្រោង )

គម្រោងនេះមានសកម្មភាពសំខាន់ៗដូចជា៖
១. ការបង្កើតឡូត៍ពិសោធន៍ប្រៀបធៀបដើមពូជចំនួន២៤ហិកតា
២. ការបង្កើតចំការបង្កាត់ពូជឈើចំនួន០៦ហិកតា
៣. ការអនុវត្តបច្ចេកទេសរុក្ខវប្បកម្មទៅលើតំបន់ស្តារព្រៃឈើចំនួន១០០ហិកតា
៤. ការបណ្តុះបណ្តាលនឹងផ្សព្វផ្សាយ
៥. ការស្រាវជ្រាវក្នុងមន្ទីរពិសោធន៍ជាលិកាវប្បកម្ម
៦. ការចងក្រងជាឯកសារបច្ចេកទេស

**១៥. យុត្តិកម្មលើគម្រោង** ( បង្ហាញពីហេតុផលថាហេតុអ្វីបានជាគម្រោងនេះត្រូវបានជ្រើសរើស )

គម្រោងនេះពិតជាមានសារៈសំខាន់សម្រាប់ការងារស្តារព្រៃឈើ ពីព្រោះចំការបង្កាត់ពូជឈើនេះ
ត្រូវបានបង្កើតឡើងដោយការជ្រើសរើសដើមពូជពីប្រភពផ្សេងៗគ្នា
យកមកដាំធ្វើការប្រៀបធៀបរកដើមពូជណាខ្លះដែលមានភាពធន់នឹងជម្ងឺ ដុះលូតលាស់លឿន មានទម្រង់ដើមល្អ មិនសូវមានមែកច្រើន
ហើយមានភាពរឹងមាំអាចទប់ទល់នឹងមជ្ឈដ្ឋានខាងក្រៅបានខ្ពស់។ ម្យ៉ាងវិញទៀត
គម្រោងកំពុងតែធ្វើការពិសោធន៍ក្នុងការផលិតកូនឈើពីជាលិកា(ជាលិកាវប្បកម្ម) ហើយប្រសិនបើទទួលបានជោគជ័យនេះ
ពិតណាស់ការផលិតកូនឈើទ្រង់ទ្រាយធំ សម្រាប់ការងារស្តារព្រៃឈើថ្នាក់ជាតិ នឹងមានភាពប្រសើរឡើង។

**១៦. ផលប្រយោជន៍របស់គម្រោង** ( រៀបរាប់ពីអ្នកដែលនឹងទទួលប្រយោជន៍ផ្ទាល់និងមិនផ្ទាល់ពីការអនុវត្តគម្រោង )

គម្រោងបានបង្កើនសមត្ថភាពមន្ត្រីរដ្ឋបាលព្រៃឈើក្នុងការងារស្រាវជ្រាវស្តីពីការបង្កាត់ពូជឈើ និងការពិសោធន៍មួយ
ចំនួនទៀតទាក់ទងនឹងការងារស្តារព្រៃឈើ។ បន្ថែមលើនេះទៀត អ្នកពាក់ព័ន្ធជាច្រើនដូចជា និស្សិត អ្នកធ្វើការលើវិស័យ ព្រៃឈើជាតិ
និងអន្តរជាតិ អាជ្ញាធរ និងប្រជាពលរដ្ឋមូលដ្ឋានដែររស់នៅជុំវិញតំបន់អនុវត្តគម្រោង សុទ្ធសឹងតែ
ទទួលបានចំណេះដឹងថ្មីៗបន្ថែមលើការងារស្រាវជ្រាវនេះ តាមរយៈការធ្វើទស្សនៈកិច្ចសិក្សា ការចូលរួមសិក្ខាសាលា កម្មសិក្សា
និងការផ្លាស់ប្តូរបទពិសោធន៍ ការទទួលបានឯកសារផ្សព្វផ្សាយជាដើម។ ក្រៅពីនេះប្រទេសកម្ពុជានឹង មានប្រភពគ្រាប់ពូជគ្រញូង ធ្នង់
និងត្រាច ដែលបានបង្កើតឡើងតាមបច្ចេកទេសមួយសម្រាប់បម្រើប្រយោជន៍ការងារស្តារព្រៃឈើ នាពេលអនាគត។

**១៧. ការសិក្សាសមិទ្ធិលទ្ធភាព**

| | |
|---|---|
| តើគម្រោងនេះតម្រូវឲ្យមានការសិក្សាសមិទ្ធិលទ្ធភាពដែរ ឬទេ? | **មាន** |
| ប្រសិនបើត្រូវការ តើការសិក្សាសមិទ្ធិលទ្ធភាព បានរៀបចំហើយឬនៅ? | **មិនទាន់ចាប់ផ្តើម** |

**១៨. ផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម** ( ពិពណ៌សង្ខេបពីផលប៉ះពាល់របស់គម្រោងលើប្រជាជននិងបរិស្ថានជុំវិញ
ប្រសិនបើមាន។ តើគម្រោងនេះនឹងជួយដល់ការកាត់បន្ថយភាពក្រីក្រដែរឬទេ? )

គម្រោងបានរួមចំណែកក្នុងការបង្កើនគម្របព្រៃឈើតាមរយៈការបង្កើតចំការប្រៀបធៀបដើមពូជ និងចំការបង្កាត់ពូជឈើចំនួន៣០ហិកតា។ គម្រោងបានបណ្តុះបណ្តាលប្រជាជនមូលដ្ឋានពាក់ព័ន្ធនឹងការទប់ស្កាត់ភ្លើងឆេះព្រៃអត្ថប្រយោជន៍របស់ព្រៃឈើ ការអនុវត្តន៍បច្ចេកទេសរុក្ខវប្បកម្មទៅលើចំការឈើដាំ និងក្នុងថ្នាលបណ្តុះកូនឈើ។ ដោយសារគម្រោងផ្តោតខ្លាំងតែលើការបង្កើតចំការពូជឈើ សកម្មភាពជម្រុញជីវភាពប្រជាជលមូលដ្ឋាន ពុំមែនជាសកម្មភាព ចម្បង ឡើយ។ ក៏ប៉ុន្តែគម្រោងក៏បានជួយសម្រួលជីវភាពប្រជាជនរស់ នៅជុំវិញទីតាំងគម្រោងតាមរយៈការចូលរួមអនុវត្តសកម្មភាពមួយចំនួនដូចជាការបណ្តុះកូនឈើ ការដាំ និងការងារថែទាំងជាដើម ដោយផ្តល់ជាប្រាក់កំលាំងពលកម្ម ដល់ពួកគាត់។

**១៩. ការប្រែប្រួល អាកាសធាតុ**

ក. តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ ទងនឹងការប្រែប្រួលអាកាសធាតុ ឬទេ? **មាន**

ប្រសិនបើទាក់ទងនឹងការប្រែប្រួលអាកាស ធាតុ សូមជ្រើសរើស **ការបន្សាំ**

ខ. តើគម្រោងមានភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុកម្រិតណា?

សូមជ្រើសរើសវិស័យដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងនិងបំពេញការចូលរួមចំណែកនៃចំណាយដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុរបស់គម្រោងធៀបនឹងតម្លៃគម្រោងសរុប។

| វិស័យដែលទាក់ទងនឹង ការប្រែប្រួលអាកាសធាតុ | ភាគរយ | ភាពទាក់ទងនឹងការប្រែប្រួល អាកាសធាតុ |
|---|---|---|
| **១១. ជីវៈចម្រុះនិងការអភិរក្ស** | 50 | **ទាក់ទងមធ្យម** |

**២០. ការកាត់បន្ថយ ហានិភ័យ និង គ្រោះមហន្តរាយ**

តើសកម្មភាព ឬធាតុចេញរបស់គម្រោងទាក់ទងនឹងការកាត់បន្ថយហានិភ័យ និងគ្រោះមហន្តរាយដែរឬទេ? **មាន**

ប្រសិនបើ ទាក់ទងនឹងការកាត់បន្ថយហានិភ័យនិងគ្រោះមហន្តរាយ សូមជ្រើសរើស **ការបង្ការ**

**២១. ការវិភាគយេនឌ័រ** (តើគម្រោងនេះមានផលប៉ះពាល់ដល់តួនាទីរបស់បុរសនិងស្ត្រីក្នុងទីតាំងរបស់គម្រោងនេះដូចម្តេច? តើស្ត្រីនឹងត្រូវចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគម្រោងនេះដែរឬទេ?)

ពុំមានការបែងចែករវាងបុរស និងស្ត្រីក្នុងការចូលរួមអនុវត្តសកម្មភាពរបស់គម្រោងទេ។ គ្រប់សកម្មភាពទាំងអស់ក្រុមការងារមានការលើកទឹកចិត្តឲ្យមានការចូលរួមទាំងបុរស និងស្ត្រី ទៅតាមគោលការណ៍សមធម៌។

**២២. សមត្ថភាពអនុវត្តគម្រោង** (តើក្រសួងមានជំនាញនិងបទពិសោធន៍គ្រប់គ្រាន់សម្រាប់អនុវត្តគម្រោងដែរឬទេ?)

ដោយសារគម្រោងនេះថ្មី និងជាគម្រោងទីមួយ ដែរធ្វើការបង្កាត់ពូជឈើព្រៃ ក្រុមការងារអនុវត្តគម្រោងត្រូវបានបណ្តុះបណ្តាលច្រើនវគ្គពាក់ព័ន្ធនឹងការងារបច្ចេកទេស។ បន្ថែមលើនេះ ក្រុមការងារបានធ្វើការសហការជាប្រចាំជាមួយ អ្នកជំនាញការនៅប្រទេសកូរ៉េ ដើម្បីជួយសម្រួលដល់ការអនុវត្តន៍សកម្មភាពមួយចំនួនរបស់គម្រោង។

**២៣. ស្ថានភាពនៃការអនុវត្តគម្រោង** (ពិពណ៌នាសង្ខេបអំពីវឌ្ឍនភាពរបស់គម្រោងនិងបង្ហាញអំពីភាពប្រឈមនានា ដែល បណ្តាលឲ្យមាន ការព្យាពេលក្នុងការអនុវត្តគម្រោង។)

គម្រោងចាប់ផ្តើមអនុវត្តពីដើមឆ្នាំ២០១៦ រហូតមកដល់ពេលនេះ សកម្មភាពភាគច្រើនប្រព្រឹត្តទៅតាមផែនការប្រចាំឆ្នាំនីមួយៗ លើកលែងតែការងារពិសោធន៍ជាលិកាវប្បកម្ម ដែលពុំទាន់មានជាលទ្ធផលអ្វីជុំកំកួននៅឡើយ។ ការងារនេះ ទាមទាររយៈពេលយូរ គួបផ្សំភាពឧស្សាហ៍ព្យាយាមរបស់មន្ត្រីក្នុងការអនុវត្តន៍ និងស្រាវជ្រាវបន្ថែមជាប្រចាំ។

**២៤. អាទិភាពរបស់គម្រោង** (បញ្ជាក់ពីការកំណត់អាទិភាពរបស់គម្រោងរបស់ក្រសួង ស្ថាប័ន)

1

**២៥. ការចូលរួមរបស់ដៃគូអភិវឌ្ឍ** (ផ្តល់ព័ត៌មានអំពីដៃគូអភិវឌ្ឍសក្តានុពល ដែលពាក់ព័ន្ធនឹងគម្រោងនេះ)

គម្រោងនេះទទួលបានការឧបត្ថម្ភថវិកាដោយ អង្គការសហប្រតិបត្តិការព្រៃឈើអាស៊ី (Asia Forest Cooperation Organization, AFoCO) និងជំនួយបច្ចេកទេសដោយអ្នកជំនាញមកពី វិទ្យាស្ថានជាតិស្រាវជ្រាវវិទ្យាសាស្ត្រព្រៃឈើកូរ៉េ (National Institute of Forest Science, NIFoS) និងសាស្ត្រាចារ្យនៃសកលវិទ្យាល័យជាតិសេអ៊ូល (Seoul National University, SNU)។

## ផ្នែក ខ ចំណាយរបស់គម្រោងនិងប្រភពហិរញ្ញប្បទាន

*(គិតជាពាន់ដុល្លារអាមេរិក)*

| ចំណាយវិនិយោគ | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | ថវិកា |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | ចរន្ត |
| **ចំណាយប្រតិបត្តិ** | 103.8 | 93.3 | 83.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| បៀវត្សរ៍ | 38.3 | 38.3 | 31.7 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សម្ភារ:និងរដ្ឋបាល | 6.0 | 6.0 | 14.4 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 59.5 | 49.0 | 37.8 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយមូលធន** | 13.0 | 11.0 | 7.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| ការសាងសង់ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| សេវាទីប្រឹក្សា | 3.0 | 3.0 | 3.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ទព្វសម្ភារ: | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ការបណ្តុះបណ្តាល | 10.0 | 8.0 | 4.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| ផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |
| **ចំណាយសរុប** | 116.8 | 104.3 | 90.9 | 0.0 | 0.0 | 0.0 | 0.0 | 0.0 |
| | | | | | | | | |

| ប្រភពហិរញ្ញប្បទាន | 2024 | | 2025 | 2026 | 2027 | 2028 | សរុប | |
|---|---|---|---|---|---|---|---|---|
| | ថវិកា | ជាក់ស្តែង | ថវិកា | ប៉ាន់ស្មាន | ប៉ាន់ស្មាន | ប៉ាន់ស្មាន | 2026-2028 | |
| | | | | | | | | |
| **ចំណូលពីគម្រោង** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ថវិកាជាតិ** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| សាច់ប្រាក់សុទ្ធ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| ធនធានផ្សេងៗ | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **ហិរញ្ញប្បទាន របស់ ដៃគូអភិវឌ្ឍ** | 116.8 | 104.3 | 90.9 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| Government of Republic of Korea | 116.8 | 104.3 | 90.9 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **សរុបហិរញ្ញប្បទាន ដែលបានសន្យាផ្តល់** | 116.8 | 104.3 | 90.9 | 0.0 | 0.0 | 0.0 | 0.0 | |
| | | | | | | | | |
| **តម្រូវហិរញ្ញប្បទាន បំពេញបន្ថែម** | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | 0.0 | |

**បានឃើញ និង ឯកភាព**

**រដ្ឋមន្ត្រី**

កាលបរិច្ឆេទ: